# ព្រះរាជក្រឹត្យ

នស/រកត/០៩២៣/ ២១៤៩

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០២១/០១៤ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី វិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ត្រូវបានតែងតាំងសមាសភាពក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដែលសរសេរជាអក្សរកាត់ថា **ក.អ.ក.** ដូចមានរាយនាមខាងក្រោម ៖

| | |
|---|---|
| ១-សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា | ជា **ប្រធាន** |
| ២-ឯកឧត្តម **ស៊ុន ចាន់ថុល** ឧបនាយករដ្ឋមន្ត្រី | ជា **អនុប្រធានទី១** |
| ៣-ឯកឧត្តម **ឈៀង យ៉ាណារ៉ា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស | ជា **អនុប្រធានទី២** |
| ៤-ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | ជា **សមាជិក** |
| ៥-ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | ជា **សមាជិក** |
| ៦-ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | ជា **សមាជិក** |
| ៧-ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជា **សមាជិក** |
| ៨-ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ជា **សមាជិក** |
| ៩-រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ជា **សមាជិក** |
| ១០-រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | ជា **សមាជិក** |
| ១១-រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | ជា **សមាជិក** |
| ១២-រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល | ជា **សមាជិក** |
| ១៣-រដ្ឋមន្ត្រីក្រសួងផែនការ | ជា **សមាជិក** |
| ១៤-រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ជា **សមាជិក** |
| ១៥-រដ្ឋមន្ត្រីក្រសួងបរិស្ថាន | ជា **សមាជិក** |
| ១៦-រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម | ជា **សមាជិក** |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

១៧-រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ជា សមាជិក
១៨-រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ជា សមាជិក
១៩-រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ជា សមាជិក
២០-រដ្ឋមន្ត្រីក្រសួងកិច្ចការនារី ជា សមាជិក
២១-រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជា សមាជិក
២២-រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ជា សមាជិក
២៣-រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន ជា សមាជិក
២៤-ទេសាភិបាលធនាគារជាតិ នៃកម្ពុជា ជា សមាជិក
២៥-ប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ជា សមាជិក
២៦-អគ្គលេខាធិការគណៈកម្មាធិការវិនិយោគកម្ពុជា ជា សមាជិក
២៧-អគ្គលេខាធិការគណៈកម្មាធិការសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា ជា សមាជិក
២៨-អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាននៃ ក.អ.ក. ជា លេខាធិការ។

**មាត្រា២ៈ** រដ្ឋមន្ត្រីក្រសួងឬប្រធានស្ថាប័នឯទៀតនៃរាជរដ្ឋាភិបាល ដែលមិនមែនជាសមាជិក **ក.អ.ក.** ត្រូវចូលរួមកិច្ចប្រជុំរបស់ **ក.អ.ក.** តាមការអញ្ជើញរបស់ប្រធាន ឬ អនុប្រធាន តាមការប្រគល់សិទ្ធិ។ រដ្ឋមន្ត្រីក្រសួង ឬ ប្រធានស្ថាប័នដែលផ្តល់សិទ្ធិឲ្យតំណាងរបស់ខ្លួនចូលរួម ត្រូវផ្តល់សិទ្ធិសម្រេចពេញលេញសម្រាប់ការពិភាក្សា និងការសម្រេច។

**មាត្រា៣ៈ** សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែកញ្ញា ឆ្នាំ២០២៣

**ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

១៣៧. ៦៣០៩. ២០២៣

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**វង្សី វិស្សុត**